# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៤៨៦
ចុះថ្ងៃទី២៤-៣-២០២០
សាលដីកា
លេខ៖ ១២៤ ក្រ.ឧ.រ
ចុះថ្ងៃទី ០៥-១០-២០២០

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ៖ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ និងបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ៖**

លោក [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

កញ្ញា ទីវ គីមកល្យាណ ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៦ ចុះថ្ងៃទី២៤-៣-២០២០ លើជនជាប់ចោទ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើករថយន្ត ទីកន្លែងកំណើតនៅភូមិថ្មី ឃុំកណ្តាលជុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្ន [redacted] កណ្តាលជុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) ជានីតិជន ទោសពីមុន គ្មាន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៩៥ ចុះថ្ងៃ២០ ខែសីហា ឆ្នាំ២០១៩។

-មានលោក អ៊ឹម ម៉ាច ជាមេធាវីការពារសិទ្ធិ។

ជាប់ចោទពីបទ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច ដែលបទបញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យរបួស និងស្លាប់អ្នកដទៃ ប្រព្រឹត្តនៅភូមិកំណាប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។





Scanned with CamScanner

**អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ឈ្មោះ [redacted] ចាន់ថា ហៅ ស្មាញ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិផ្សារត្រពាំងក្រឡឹង ឃុំតិរវ័ន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted])។

**ជនរងគ្រោះ**

១. ឈ្មោះ [redacted] រតនា ភេទស្រី អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

២. ឈ្មោះ [redacted] វិច្ឆិកា ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

៣. ឈ្មោះ [redacted] សុភា ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិក្រស់សាលាក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ ✓

**ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ចន្ទី ហៅ បារាំង ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។✓

**ដើមបណ្តឹងរដ្ឋប្បវេណី**

១. ឈ្មោះ [redacted] យឹម ភេទស្រី អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

២. ឈ្មោះ [redacted] រតនា ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិរំលេច ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៣. ឈ្មោះ [redacted] វុទ្ធថា ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិក្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

៤. ឈ្មោះ [redacted] សាវុធ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**ឯករឿងហេតុមានដូចតទៅ÷**

កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ៤០នាទី នៅលើផ្លូវលេខ ១៣០ ត្រង់ចំណុចលើស្ពានអំពែភ្នំភូមិកំណប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានករណីបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិ ស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យរបួស និងស្លាប់អ្នកដទៃ ដែលបង្កឡើងដោយអ្នកបើករថយន្តម៉ាក HINO ពណ៌ខៀវ ពាក់ផ្លាកលេខ ភ្នំពេញ 3A-3547 បើកបរដោយឈ្មោះ [redacted] ចាន់ថា ភេទប្រុស អាយុ២២ឆ្នាំ ដោយអ្នកបើកបរមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តឲ្យ

បានច្បាស់លាស់ បើកបរដោយគ្មានប័ណ្ណបើកបរ បើកក្នុងល្បឿនលឿន ដោយជាន់ហ្វ្រាំងមិនស៊ី ក៏បានបើកទៅបុករថយន្តមួយគ្រឿងទៀតម៉ាក HYUNDAI ពណ៌ស ពាក់ផ្លាកលេខ កំពង់ចាម 3A-5305 បើកដោយឈ្មោះ [redacted] ចិត្រ កំពុងតែឡើងលើស្ពាន បុករុញថយក្រោយទៅបុកម៉ូតូពីរគ្រឿងទៀតធ្វើឲ្យអ្នកជិះម៉ូតូម្នាក់ឈ្មោះ [redacted] រតនា ភេទស្រី អាយុ១៦ឆ្នាំ បានស្លាប់ ឈ្មោះ [redacted] វិច្ឆិកា ភេទស្រី ឈ្មោះ [redacted] បុភា ភេទស្រី រងរបួសធ្ងន់ និងឈ្មោះ [redacted] ចន្ទី ភេទស្រី រងរបួសស្រាល។

**-បានឃើញ សាលក្រមលេខ ៩៤(ខ) ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ÷**

១.ផ្តន្ទាទោសឈ្មោះ [redacted] ចាន់ថា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកបររថយន្ត ទីកន្លែងកំណើតនៅភូមិថ្មី ឃុំកណ្តាលជុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន ភូមិថ្មី សង្កាត់កណ្តាលជុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ( រ) ម្តាយឈ្មោះ [redacted] ជានីតិជន ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារចំនួន ០៣(បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ពីបទ: បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បុមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យរបួស និងស្លាប់អ្នកដទៃ ប្រព្រឹត្តនៅភូមិកំណាប់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២. ប្រគល់: ម៉ូតូហុងដា C125 ពណ៌ខ្មៅ ស៊េរី ២០០៨ ពាក់ផ្លាកលេខ កំពង់ស្ពឺ 1B-7614 ឲ្យឈ្មោះ [redacted] វិច្ឆិកា។

៣. ប្រគល់: ម៉ូតូហុងដា C125 ពណ៌ខ្មៅ ស៊េរី ២០១៥ ពាក់ផ្លាកលេខ កំពង់ស្ពឺ 1J-6910 ឲ្យឈ្មោះ [redacted] ចាន់ធី ។

៤. ឲ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជម្ងឺជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

៥. ឲ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជម្ងឺជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិប) លានរៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឹម ។បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល។

៦. ឲ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជម្ងឺជាប្រាក់ចំនួន ៨.០០០.០០០(ប្រាំបី)លានរៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុធ។ បណ្តឹងទាមទារ សុំលើសពីនេះ បដិសេធចោល។



Scanned with CamScanner

៧. ឲ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជម្ងឺជាប្រាក់ចំនួន ៦.០០០.០០០(ប្រាំមួយលាន)រៀល មកឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុទ្ធថា។ បណ្ដឹងទាមទារ សុំលើសពីនេះ បដិសេធចោល។

៨. ឲ្យឈ្មោះ [redacted] ចាន់ថា ដែលមានសាវតាជាតិដូចខាងលើ បង់សំណងថ្លៃព្យាបាលរបួស និងជម្ងឺជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល មកឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ទី ។ បណ្ដឹងទាមទារ សុំលើសពីនេះ បដិសេធចោល។

៩. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ថា ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម, ឈ្មោះ [redacted] សាវុធ, ឈ្មោះ [redacted] វុទ្ធថា, ឈ្មោះ [redacted] ចន្ទី និងចាត់ទុកចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា និងកំបាំងមុខឈ្មោះ [redacted] តនា។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨ (ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨ (ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ថា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨(ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃលើសេចក្ដីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ។

-បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង**

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ថា (វត្តមាន)

-លោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ (វត្តមាន)

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា (អវត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម (អវត្តមាន)



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា ឆ្លើយថា៖ ខ្លួនប្តឹងឧទ្ធរណ៍មកនេះដោយមិនសុខចិត្ត ចំពោះការសម្រេចរបស់សាលាដំបូងខេត្តកំពង់ស្ពឺ ដោយហេតុថា ខ្លួនបើកឡានដឹកថ្ម ហើយឡាន Hyundai បានថយក្រោយបុកម៉ូតូរបស់ជនរងគ្រោះ។ ឡានរបស់ខ្លួន បានមកដល់ពាក់កណ្តាលស្ពាន ហើយឡានគេថយក្រោយប៉ះម៉ូតូនោះ។ ឈ្មោះ [redacted] ចាន់ថា ជាបងរបស់ខ្លួន ហើយក៏ត្រូវជាម្ចាស់ឡាន។ ឡានរបស់បងខ្លួនមានពីរទៅបីគ្រឿង ខ្លួនជួយបើកឡានអោយបងខ្លួន។ ខ្លួនគ្មានប័ណ្ណបើកបរទេ ។ ខ្លួនបើកឡានតាំងពីអាយុ១៨ឆ្នាំមកម្លេះ។ ខ្លួនបើកឡានមានស្លាកលេខ 3A 3547 ឡានប៉ះគឺឡានម៉ាក Hyundai ថយក្រោយប៉ះគេស្លាប់ ទើបខ្លួនបុកបន្តិចតាមក្រោយ ខ្លួនព្យាយាមជាន់ហ្វ្រាំងដែរ តែជាន់មិនស៊ី។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖

ជនជាប់ចោទប្តឹងឧទ្ធរណ៍ដោយធ្វើការស្នើសុំ បន្ធូរបន្ថយទណ្ឌកម្មដែលសាលាដំបូង បានផ្តន្ទាទោស។ ការផ្តន្ទាទោសរបស់សាលាដំបូងខេត្តកំពង់ស្ពឺគឺមានលក្ខណៈសមរម្យហើយ ព្រោះគាត់គ្មានប័ណ្ណបើកបរ ហើយជនជាប់ចោទដឹងថាហ្វ្រាំងឡាន របស់ខ្លួនអត់ស៊ីតែព្យាយាមបើកទៀត។ តំណាងមហាអយ្យការស្នើសុំ តម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ស្ពឺទុកជាបានការដដែល ហើយចំពោះព្យសនកម្មស្នើសុំឲ្យក្រុមប្រឹក្សាមេត្តាពិចារណាតាមជាក់ស្តែង។

## មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖

កូនក្តីរបស់ខ្លួនបានធ្វើការបើកបរដល់កន្លែងកើតហេតុ គឺគាត់បានឆ្លងស្ពានជិតផុតទៅហើយ ការបើកបរលើស្ពានគឺយឺតៗ ដោយប្រើលេខ ២ ហើយចំងាយមិនរាចជាន់ហ្វ្រាំងទាន់។ ឡានធំដែលថយ មើលមិនឃើញម៉ូតូខាងក្រោយ គឺជាឡានផ្សេង។ យោងតាមកោសល្យវិច័យ អ្នកបើកបរ Hyundai គឺមិនផ្តល់អត្ថិភាពចំពោះយានយន្តដែលនៅលើស្ពានឡើយ។ ក្រោយកើតហេតុអ្នកបើកបរឈ្មោះ វិចិត្រ បានរត់គេចខ្លួនបាត់ ពេលមានឧបសគ្គជាន់ហ្វ្រាំងមិនស៊ី ហើយចោទប្រកាន់លើកូនក្តីរបស់ខ្លួន ដោយអោយកូនក្តីរបស់ខ្លួនជាអ្នកសងសំណងទៅជនរងគ្រោះ។ ការស្លាប់របស់ជនរងគ្រោះ គឺដោយសារឡានថយដោយខ្លួនឯង។ ចំពោះការពិន័យ និងទណ្ឌកម្មរបស់សាលាដំបូងខេត្តកំពង់ស្ពឺ គឺមានលក្ខណៈធ្ងន់ធ្ងរ ដោយគាត់ទើបតែប្រព្រឹត្តអំពើល្មើសនេះជាលើកទី ១ ។ ស្នើសុំអោយ ក្រុមប្រឹក្សាជំនុំជម្រះមេត្តាបន្ធូរបន្ថយទោស និងព្យួរទណ្ឌកម្ម រួមទាំងអោយកូនក្តីរបស់ខ្លួនរួចផុតពីទណ្ឌកម្មពិន័យដោយក្តីអនុគ្រោះ។

## សំណូមពររបស់ជនជាប់ចោទ៖

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា សំណូមពរ សុំបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned with CamScanner

## សាលាឧទ្ធរណ៍ភ្នំពេញ

### យល់ឃើញថាៈ

១/.បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ថា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨(ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងពុំបានត្រឹមត្រូវតាមកំណត់ច្បាប់ នៃមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ គឺធ្វើឡើងហួសរយៈពេលកំណត់។ ដូច្នេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ ប្រកាសថាៈ បណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបាន តាមបញ្ញត្តិនៃមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២/.បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨(ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៨៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៣៧៥ មាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ នៃច្បាប់ស្តីពីពិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះទទួលជំនុំជម្រះបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា។

៣/.បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៨(ង) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៨៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៣៧៥ មាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ នៃច្បាប់ស្តីពីពិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះទទួលជំនុំជម្រះបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា។

៤/.ការដែលសាលាដំបូង បានសម្រេចឲ្យឈ្មោះ [redacted] ចាន់ថា ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីនោះ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិនៃមាត្រា៧៨៧ នៃក្រមរដ្ឋប្បវេណី ព្រោះជនជាប់ចោទឈ្មោះ [redacted] ចាន់ថា ជាអ្នកស៊ីឈ្នួលបើកឡានដឹកថ្មឲ្យឈ្មោះ [redacted] ចាន់ថា ។ ម្យ៉ាងទៀត ការដែលសាលាដំបូងបានសម្រេចឲ្យឈ្មោះ [redacted] ចាន់ថា សងសំណងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីៈ

ក-ឈ្មោះ [redacted]ឃីម ចំនួន ៨០.០០០.០០០ (សែសិបលាន)រៀល ដែលកូនបានទទួលរងនូវគ្រោះថ្នាក់ចរាចរណ៍ រហូតដល់មរណភាព ។

ខ-ឈ្មោ[redacted]រតនា ចំនួន ៤.០០០.០០០ (បួនលាន)រៀល ។

គ-ឈ្មោះ [redacted] សាវុធ ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល ។

ឃ-ឈ្មោះ [redacted]ទូថា ចំនួន ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ង-ឈ្មោះ [redacted]ចន្ទី ចំនួន ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ឃើញថា មានលក្ខណៈសមរម្យទៅនឹងកម្រិតជីវភាពជាក់ស្តែង បើប្រៀបធៀបនឹងព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាន់ថា។ ដូចនេះ ក្រុមប្រឹក្សាជំនុំជម្រះ ពុំអាចពិចារណាពីសំណងរដ្ឋប្បវេណីឡើងវិញ តាមបណ្តឹងឧទ្ធរណ៍របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា និងតាមបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម ។



Scanned with CamScanner

៥/.សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍រាជធានីភ្នំពេញតម្កល់ទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១/.បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធា មិនអាចទទួលយកបាន។

២/.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា ។

៣/.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានចំពោះផ្នែកអាជ្ញា ។

៤/.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ង" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។

៥/.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៦/.សាលដីកានេះជំនុំជម្រះជាសាធារណៈថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ កំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថា និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃីម ។

-ទុកសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted], [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ១២ កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០២០

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]